**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៣៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៣៤២,៥៤ ហិកតា នៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ចេញពីគម្របព្រៃឈើ ឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ១១៧ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ



www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ០៨៦អបខចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តកំពង់ស្ពឺ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

### មាត្រា ១.-

ត្រូវបានកាត់ដីទំហំ ៣៤២,៥៤ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មទំហំ ២៥៤,៨២ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ៨៧,៧២ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិតាំងបំពង់ ឃុំ តាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

### មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១១៧ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅភូមិតាំងបំពង់ ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។



www.pheakdeylaw.com

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គមនៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*



www.pheakdeylaw.com

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ...៣៤ អនក្រ.បក... ចុះថ្ងៃទី...២៤...ខែ...កុម្ភៈ...ឆ្នាំ២០១៣ ស្តីពីការកាត់ឆ្វៀលផ្ទៃដីសរុបទំហំ ៣៤២,៥៥ ហិកតា ចេញពីតំបន់គម្របព្រៃឈើឆ្នាំ២០០២ ដែលក្នុងនោះត្រូវបានធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ២៥៤,៨២ ហិកតា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងរស់នៅជាក់ស្តែងចំនួន ១១៧ គ្រួសារ និងទុកជាដីសាធារណៈរបស់រដ្ឋ ទំហំ ៨៧,៧២ ហិកតា នៅភូមិតាំងចំរេះ ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ




តារាងកូអរដោនេ

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 371210 | 1208607 | 53 | 371766 | 1297309 | 105 | 373566 | 1205732 |
| 2 | 371038 | 1208821 | 54 | 371626 | 1297380 | 106 | 373682 | 1205765 |
| 3 | 370834 | 1208661 | 55 | 371628 | 1297450 | 107 | 373846 | 1205850 |
| 4 | 371078 | 1208117 | 56 | 371568 | 1297423 | 108 | 373774 | 1206036 |
| 5 | 371023 | 1207822 | 57 | 371591 | 1297394 | 109 | 373970 | 1205905 |
| 6 | 370932 | 1207616 | 58 | 371716 | 1297279 | 110 | 374247 | 1206120 |
| 7 | 370558 | 1207484 | 59 | 371428 | 1297277 | 111 | 374376 | 1206013 |
| 8 | 371106 | 1207411 | 60 | 371436 | 1297382 | 112 | 374367 | 1206178 |
| 9 | 371285 | 1207158 | 61 | 373008 | 1206488 | 113 | 374473 | 1206173 |
| 10 | 371538 | 1207068 | 62 | 373052 | 1206394 | 114 | 374490 | 1206060 |
| 11 | 371459 | 1207046 | 63 | 372955 | 1206351 | 115 | 374604 | 1205704 |
| 12 | 371528 | 1206604 | 64 | 372910 | 1206256 | 116 | 374711 | 1205946 |
| 13 | 371470 | 1206782 | 65 | 372707 | 1206200 | 117 | 374601 | 1205970 |
| 14 | 371432 | 1205723 | 66 | 372580 | 1296158 | 118 | 374688 | 1206168 |
| 15 | 371205 | 1206504 | 67 | 372280 | 1296089 | 119 | 374584 | 1206305 |
| 16 | 371225 | 1206294 | 68 | 372934 | 1296040 | 120 | 374639 | 1205503 |
| 17 | 371222 | 1295750 | 69 | 373036 | 1205085 | 121 | 374374 | 1206505 |
| 18 | 371047 | 1295704 | 70 | 373228 | 1295898 | 122 | 374230 | 1206410 |
| 19 | 370393 | 1205605 | 71 | 373260 | 1295767 | 123 | 374224 | 1206330 |
| 20 | 370770 | 1205604 | 72 | 373383 | 1295754 | 124 | 374058 | 1206505 |
| 21 | 370508 | 1205670 | 73 | 373253 | 1295416 | 125 | 374082 | 1206494 |
| 22 | 370515 | 1205754 | 74 | 373092 | 1205454 | 126 | 374107 | 1206388 |
| 23 | 370360 | 1205803 | 75 | 373095 | 1205340 | 127 | 374050 | 1206370 |
| 24 | 370208 | 1205807 | 76 | 372915 | 1295290 | 128 | 373940 | 1206320 |
| 25 | 370431 | 1295521 | 77 | 372063 | 1295270 | 129 | 373845 | 1206251 |
| 26 | 370550 | 1205462 | 78 | 373113 | 1205292 | 130 | 373650 | 1206704 |
| 27 | 370723 | 1295570 | 79 | 373120 | 1205027 | 131 | 373730 | 1205587 |
| 28 | 370825 | 1206244 | 80 | 372011 | 1205028 | 132 | 373762 | 1205410 |
| 29 | 371147 | 1205053 | 81 | 372724 | 1295093 | 133 | 373931 | 1205532 |
| 30 | 371426 | 1206000 | 82 | 372610 | 1205040 | 134 | 373812 | 1205595 |
| 31 | 371307 | 1206136 | 83 | 372457 | 1204915 | 135 | 373720 | 1205267 |
| 32 | 371600 | 1205110 | 84 | 372400 | 1294840 | 136 | 373760 | 1206107 |
| 33 | 371705 | 1295250 | 85 | 372394 | 1294720 | 137 | 373026 | 1206105 |
| 34 | 371901 | 1295410 | 86 | 372610 | 1204686 | 138 | 373958 | 1206220 |
| 35 | 371908 | 1205528 | 87 | 372810 | 1204911 | 139 | 373976 | 1206302 |
| 36 | 371762 | 1205674 | 88 | 372610 | 1295005 | 140 | 374047 | 1205320 |
| 37 | 371704 | 1205811 | 89 | 372007 | 1204918 | 141 | 374082 | 1205201 |
| 38 | 371989 | 1205745 | 90 | 373070 | 1204853 | 142 | 374141 | 1205304 |
| 39 | 372193 | 1205708 | 91 | 373077 | 1204064 | 143 | 374255 | 1205515 |
| 40 | 372067 | 1295533 | 92 | 373021 | 1204593 | 144 | 374338 | 1205655 |
| 41 | 372065 | 1205363 | 93 | 372853 | 1204020 | 145 | 374426 | 1205643 |
| 42 | 372275 | 1205300 | 94 | 372662 | 1204563 | 146 | 374472 | 1205581 |
| 43 | 372353 | 1295740 | 95 | 373050 | 1204030 | 147 | 374400 | 1205762 |
| 44 | 372220 | 1205870 | 96 | 373148 | 1204074 | 148 | 374410 | 1205775 |
| 45 | 372111 | 1205928 | 97 | 373104 | 1204062 | 149 | 374300 | 1206585 |
| 46 | 372092 | 1206037 | 98 | 373212 | 1204070 | 150 | 374166 | 1205677 |
| 47 | 371961 | 1296340 | 99 | 373192 | 1295021 | 151 | 374211 | 1205503 |
| 48 | 371722 | 1206651 | 100 | 373228 | 1295207 | 152 | 374164 | 1205414 |
| 49 | 371668 | 1206043 | 101 | 373389 | 1295335 | 153 | 373909 | 1205544 |
| 50 | 371461 | 1207204 | 102 | 373347 | 1205443 | 154 | 373916 | 1205605 |
| 51 | 371717 | 1207262 | 103 | 373400 | 1205665 | | | |
| 52 | 371757 | 1207269 | 104 | 373531 | 1205637 | | | |